**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# រយៈពេល ៣ ឆ្នាំ
# (២០១៩ - ២០២១)

ឈ្មោះសហគមន៍នេសាទ ៖ ក្រូចឆ្មារ

ភូមិ ៖ ក្រូចឆ្មារលើ ក្រូចឆ្មារក្រោម ខ្សាច់ប្រឆេះកណ្តាល ខ្សាច់ប្រឆេះលើ ខ្សាច់ប្រឆេះក្រោម ដើមជ្រៃ សំរោង

ឃុំ ៖ ក្រូចឆ្មារ

ស្រុក ៖ ក្រូចឆ្មារ

ខេត្ត ៖ ត្បូងឃ្មុំ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# រយៈពេល ៣ ឆ្នាំ
# (២០១៩ - ២០២១)

ឈ្មោះសហគមន៍នេសាទ ៖ ក្រូចឆ្មារ

ភូមិ ៖ ក្រូចឆ្មារលើ ក្រូចឆ្មារក្រោម ខ្សាច់ប្រឆេះកណ្តាល ខ្សាច់ប្រឆេះលើ ខ្សាច់ប្រឆេះក្រោម ដើមជ្រៃ សំរោង

ឃុំ ៖ ក្រូចឆ្មារ

ស្រុក ៖ ក្រូចឆ្មារ

ខេត្ត ៖ ត្បូងឃ្មុំ

# មាតិកា
# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


១. ស្ថានភាពទូទៅ ........ 1

២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម ........ 1

ក- ប្រជាសាស្ត្រ ........ 1

ខ- មុខរបរ ........ 2

៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍ ........ 2

ក- ទីតាំង ........ 2

ខ- ដែននេសាទ ........ 2

គ- តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........ 3

ឃ- ធនធានជលផល ........ 3

៤. ការធ្វើនេសាទ ........ 4

ក- អ្នកនេសាទ ........ 4

ខ- ឧបករណ៍នេសាទ ........ 4

គ- ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ ........ 5

៥. ផែនការគ្រប់គ្រងសហគមន៍នេសាទ ........ 5

ក- ទស្សនៈវិស័យ ........ 5

ខ- គោលបំណង ........ 5

គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ 6

គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ ........ 6

គ២-ផែនការកែលំអដែននេសាទ ........ 10

គ៣-ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ........ 11

គ៤-ផែនការល្បាតទប់ស្កាត់បទល្មើសជលផល ........ 11

គ៥-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ........ 12

គ៦-ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ ........ 12

គ៧-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ........ 14

ឃ- ផែនការយុទ្ធសាស្ត្រ ........ 15

តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ក្រូចឆ្មារ រយៈពេល ៣ឆ្នាំ (២០១៩ដល់២០២១) ........ 16

តារាងកម្មវិធីការងារ ........ 19

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១. ស្ថានភាពទូទៅ

សហគមន៍នេសាទក្រូចឆ្មារបានកកើតឡើង ដោយមហាសន្និបាតកំណើតលើកដំបូងនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ ដែលមានការឧបត្ថម្ភគាំទ្រពីនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទនៃរដ្ឋបាលជលផលសហការជាមួយខណ្ឌរដ្ឋបាលជលផលត្បូងឃ្មុំ និងអាជ្ញាធរដ្ឋបាលភូមិ ឃុំក្រូចឆ្មារ។

សហគមន៍នេសាទក្រូចឆ្មារមានទីតាំងស្ថិតនៅក្នុងភូមិក្រូចឆ្មារលើ ក្រូចឆ្មារក្រោម សំរោង ដើមជ្រៃ ខ្សាច់ប្រឆេះកណ្តាល ខ្សាច់ប្រឆេះលើ ខ្សាច់ប្រឆេះក្រោម ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ មានគណៈកម្មការសហគមន៍នេសាទចំនួន១១នាក់ (ស្រីគ្មាន) និងក្រុមល្បាតមួយក្រុមមានចំនួន១០នាក់ ហើយមានសមាជិកសហគមន៍នេសាទសរុបទាំងអស់ចំនួន១៤០នាក់ ប្រុសចំនួន៥៥នាក់ និងស្រីចំនួន៨៥នាក់ ក្នុងនោះមានគ្រួសារសរុបចំនួន១៤០គ្រួសារ។

កន្លងមកសហគមន៍នេសាទនេះ បានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមានៈ

- រៀបចំធ្វើមហាសន្និបាតបង្កើតសហគមន៍នេសាទ
- រៀបចំរចនាសម្ពន្ធគណៈកម្មការសហគមន៍នេសាទ និងបង្កើតក្រុមល្បាត
- រៀបចំបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ
- រៀបចំលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- កំណត់ព្រំប្រទល់ និងធ្វើផែនទីកន្លែងនេសាទសហគមន៍
- រៀបចំសេចក្តីព្រាងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- ចុះល្បាត តាមដាន និងទប់ស្កាត់បទល្មើសជលផលនៅក្នុងកន្លែងនេសាទសហគមន៍
- ចូលរួមក្នុងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពគណកម្មការសហគមន៍នេសាទ
- ចូលរួមប្រជុំជាមួយអាជ្ញាធរដ្ឋបាលភូមិ ឃុំ
- ប្រមូលព័ត៌មានទូទៅសម្រាប់ធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

ក- ប្រជាសាស្ត្រ

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទ៨៨៧៨នាក់ ប្រុស៤២២៤នាក់ ស្រី៤៦៥៤នាក់ ក្នុងនោះមានជនជាតិខ្មែរចំនួន៨៥៩៨នាក់ ខ្មែរឥស្លាម២៨០នាក់ និងអាណិកជនវៀតណាមគ្មាន។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន៤៧០នាក់
- ចំនួនពោះម៉ាយក្នុងសហគមន៍នេសាទមាន១១៣នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន៣៩នាក់ ស្រី២១នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ២២៨នាក់ ស្រី១៣៨នាក់
- ចំនួនអ្នកមានជំងឺរាំរ៉ៃក្នុងសហគមន៍នេសាទមាន ៤៤នាក់ ស្រី២៨នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ៩៧% ក្រៅពីនេះមានអ្នកកាន់សាសនាអ៊ីស្លាមប្រមាណ ៣% និងសាសនាកាតុលិកប្រមាណ គ្មាន។

- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់ អ្នកមិនចេះអក្សរចំនួន៤៩៦នាក់ ស្រី២៨៦នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន៨៨៣នាក់ ស្រី៤២៥នាក់ និងកម្រិតមធ្យមសិក្សាចំនួន ៣៦៨នាក់ ស្រី១៩៩នាក់ និងកម្រិតថ្នាក់ឧត្តមសិក្សាចំនួន៣៦៤នាក់ ស្រី១៩៧នាក់ ។

ខ- មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះ រួមមាន៖

- ធ្វើនេសាទចំនួន ១៦៧គ្រួសារ
- ធ្វើស្រែចំនួន ១០៩៩គ្រួសារ ទំហំផ្ទៃដី៧៥៨ហិកតា
- ធ្វើវារីវប្បកម្មចំនួន ៧គ្រួសារ ចំនួន២ហិកតា
- ជាងផ្ទះចំនួន ២៤គ្រួសារ
- ធ្វើចំការចំនួន ១២៥គ្រួសារ ទំហំផ្ទៃដី៤៨៨ហិកតា
- ចិញ្ចឹមសត្វចំនួន ១១៧៣គ្រួសារ
- លក់ដូរចំនួន ១២២គ្រួសារ
- កម្មករចំនួន ១១៦គ្រួសារ
- មន្ត្រីរាជការចំនួន ៨៦គ្រួសារ
- ប្រាក់ចំណូលជាមធ្យមក្នុងគ្រួសារប្រចាំឆ្នាំ មានចំនួន៤.៨៥០.០០០រៀល។

## ៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

ក- ទីតាំង

កន្លែងនេសាទសហគមន៍ក្រូចឆ្មារជាកន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណីក្នុងដែននេសាទទឹកសាបមានទំហំ២៦៤៦ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់ ៖

- ខាងជើងទល់និងផ្លូវលំ ឃុំក្រូចឆ្មារ ស្រុកក្រូចឆ្មារ
- ខាងត្បូងទល់និងឃុំទួលស្នួល ស្រុកក្រូចឆ្មារ
- ខាងកើតទល់និងឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ
- ខាងលិចទល់និងឃុំទ្រា ស្រុកក្រូចឆ្មារ

ខ- ដែននេសាទ

កន្លែងនេសាទសហគមន៍**ក្រូចឆ្មារ** មានបឹងចំនួន១១ ព្រែកចំនួន០២ និងមានទំនាបលិចទឹកក្នុងរដូវជំនោរឡើង និងនាទីព្រៃលិចទឹកគឺ៖

- បឹងអាទាំង មានទំហំប្រហែល១០ហិកតា នេសាទពេញមួយឆ្នាំ
- បឹងផ្គះ មានទំហំប្រហែល៥ហិកតា នេសាទពេញមួយឆ្នាំ
- បឹងជុំសែន មានទំហំប្រហែល៥ហិកតា នេសាទពេញមួយឆ្នាំ

- បឹងខ្យង មានទំហំប្រហែល៥ហិកតា នៃសាទពេញមួយឆ្នាំ
- បឹងរាំង មានទំហំប្រហែល៥ហិកតា នៃសាទពេញមួយឆ្នាំ
- បឹងក្រពើម៉ឺន មានទំហំប្រហែល៤ហិកតា នៃសាទពេញមួយឆ្នាំ
- បឹងកក់ មានទំហំប្រហែល៣ហិកតា នៃសាទពេញមួយឆ្នាំ
- បឹងប្រឆេះ មានទំហំប្រហែល៣ហិកតា នៃសាទពេញមួយឆ្នាំ
- បឹងតាមោក មានទំហំប្រហែល២ហិកតា នៃសាទពេញមួយឆ្នាំ
- បឹងអួរកំប្រុក មានទំហំប្រហែល៤ហិកតា នៃសាទពីខែកក្កដា ដល់ខែកុម្ភៈ
- បឹងតូច មានទំហំប្រហែល៣ហិកតា នៃសាទពីខែមិថុនា ដល់ខែមីនា
- ព្រែកតាខ្ទង មានបណ្តោយប្រហែល៥០០ម៉ែត្រ និងទទឹង១២ម៉ែត្រ នៃសាទពីខែកក្កដា ដល់ខែមករា
- ព្រែកចាស់ មានបណ្តោយប្រហែល៥០០០ម៉ែត្រ និងទទឹង១៥ម៉ែត្រ នៃសាទពីខែកក្កដា ដល់ខែមករា
- ទំនាបលិចទឹកក្នុងរដូវជំនន់ឡើង និងនាទីព្រៃលិចទឹក មានទំហំប្រហែល ២៥៨៩ហិកតា។

គ- តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

- អន្លង់បឹងអាទាំង មានទំហំ២ហិកតា (បណ្តោយ២០០ម៉ែត្រ និងទទឹង១០០ម៉ែត្រ)។

ឃ- ធនធានជលផល

- ប្រភេទត្រី (ត្រីរ៉ស់ ត្រីឆ្លាំង ត្រីឆ្តោ ត្រីប្រា ត្រីពោ ត្រីកែស ត្រីក្រម៉ម ត្រីតាអោន ត្រីក្អែក ត្រីក្រឡង់ ត្រីសណ្តាយ ត្រីអណ្តែង ត្រីដំរី ត្រីឆ្លូញ ត្រីស្លាត ត្រីកំភ្លៀវ ត្រីខ្ទឹង ត្រីកញ្ចុនជ័យ ត្រីខ្មាន់ ត្រីឈ្មៀត ត្រីកញ្ជ្រូក ត្រីបណ្តូលអំពៅ ត្រីច្រកែង ត្រីកាហែ ត្រីក្រាយ ត្រីខ្ទឹង ត្រីព្រួល ត្រីទ្រនេន ត្រីត្រសក់ ត្រីគល់រាំង ត្រីកន្ត្រប ត្រីកន្ត្របខ្លា ត្រីកញ្ចុះ ត្រីលិញ ត្រីក្រាញ់ ត្រីចង្វា ត្រីផ្ទោង ត្រីអាចម៍កុក ត្រីស្លឹកឬស្សី ត្រីក្លាំងហាយ ត្រីកន្ធរ ត្រីក្រឹម ត្រីក្រឹមទន្សាយ ត្រីស្រកាក្តាម ត្រីលលកសរ ត្រីឆ្ពិន ត្រីបណ្តូលចេក ត្រីព្រលូង ត្រីកំពត ត្រីក្រពាត់ ត្រីក្រុស ត្រីកញ្ច្រាញ់ច្រាស់ ត្រីកំភ្លាញ កំពឹស បង្កង,.....។ល។)
- ប្រភេទវារីសត្វ (អន្ទង់ កង្កែប អណ្តើក ពស់ ខ្យងគូចស្រួច ខ្យងគូចទាល ខ្យងមាស(ខ្យងពណ៌លឿង) ខ្ចៅ លៀស គ្រំប៉ោក គ្រំចំពុះទា ក្តាម កន្ធាយ ភេ,......។ល។
- ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ (ដើមរាំង ភ្នំភ្លើង ប្របួយមេ ប្របួយឈ្មោល ថ្លើមអណ្តើក អួយយ៉ាស់(បន្លាយយួន) អញ្ចាញ កន្សែង ស្នែងក្របី ស្នួលទឹក ច្រកែង ប្រផេញ ផ្តៅ ភ្នែកព្រាប បាក់ដង កន្ទៀវ ធ្មេញត្រីញី ទៀនព្រៃ ត្រស់ ថ្វាង ត្ន ខ្នាយមាន់ វល្លិប្រេង វល្លិទឹកដោះ វល្លិត្រដិត វល្លិ ដោះគន់ វល្លិត្រី វល្លិត្អើក ល្អាក់ទឹក ស្លាបទា កន្ទាំងហៃ រញ្ជា ស្នោ ស្លត់ បន្លាឃ្លេ ផ្ទោល ថ្វាន់ ត្រដក់ កន្ទុយអន្ទង់ ពោះក្អម ត្រកួន ព្រលិតអាចមន៍មាន់ ព្រលិតដូង រំចង់ ស្គន់អំបោះ ត្រាវអណ្តែត ស្មៅអន្ទត់ទឹក ស្មៅអំពៅឡៀប ចំបុលង កក់ជ្រុង កក់ក្តាម ឈូក ចន្ទល់ភ្នំ(វល្លិថ្កាល់ត្រី) កញ្ឆែត ស្មៅថ្នក់ទឹក ស្គន់ដំរី វល្លិអណ្តាតត្រកួត ក្រចាប់ សារាយ កំប្លោក ចកតូច ចកធំ កំពីងពួយស កំពីងពួយក្រហម ។ល។)

## ៤. ការធ្វើនេសាទ

ក- អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន១៣៥ នាក់ ស្រី១៤នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន២៥៤នាក់ ស្រី១៩នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន៧៥នាក់ ស្រី៥នាក់

ខ- ឧបករណ៍នេសាទ

- ឧបករណ៍នេសាទ និងទូករបស់សមាជិកសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ២០ | ១៥០ម-៣០០ម/ គ្រួសារ | ៦០០០ម៉ែត្រ | ពេញមួយឆ្នាំ |
| សន្ទូចរនង | ផ្លែ | ២០ | ៥០០-១០០០ផ្លែ / គ្រួសារ | ២០០០០ផ្លែ | ខែកញ្ញា-ខែមករា |
| សន្ទូចបង្កៃ | ផ្លែ | ៥ | ៥០-២៥០ផ្លែ / គ្រួសារ | ១២៥០០ផ្លែ | ខែវិច្ឆិកា-ខែមករា |
| លប | គ្រឿង | ១០ | ៤០-៦០គ្រឿង/គ្រួសារ | ៦០០គ្រឿង | ខែវិច្ឆិកា-ខែឧសភា |
| លាន់ | គ្រឿង | ១០ | ៥០-៦០គ្រឿង/គ្រួសារ | ៦០០គ្រឿង | ខែកញ្ញា-ខែវិច្ឆិកា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កម្លាំងសេះ |
|---|---|---|---|
| ទូកម៉ាស៊ីន | ២០គ្រឿង | ២០០-៥០០គីឡូក្រាម | ៦,៥-១៣សេះ |
| | | | |

- ឧបករណ៍នេសាទ និងទូករបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ១៥០ | ១៥០ម-៣០០ម/ គ្រួសារ | ៤៥០០០ម៉ែត្រ | ពេញមួយឆ្នាំ |
| សន្ទូចរនង | ផ្លែ | ៧០ | ៥០០-១០០០ផ្លែ/ គ្រួសារ | ៧០០០០ផ្លែ | ខែកញ្ញា-ខែមករា |
| សន្ទូចបង្កៃ | ផ្លែ | ១០០ | ៥០-២៥០ផ្លែ/ គ្រួសារ | ២៥០០០ផ្លែ | ខែវិច្ឆិកា-ខែមករា |
| លប | គ្រឿង | ៨០ | ៤០-៦០គ្រឿង/គ្រួសារ | ៤៨០០គ្រឿង | ខែវិច្ឆិកា-ខែឧសភា |
| លាន់ | គ្រឿង | ៣០ | ៥០-៦០គ្រឿង/គ្រួសារ | ១៨០០គ្រឿង | ខែកញ្ញា-ខែវិច្ឆិកា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កម្លាំងសេះ |
|---|---|---|---|
| ទូកម៉ាស៊ីន | ១០០គ្រឿង | ២០០-៥០០គីឡូក្រាម | ៦,៥-១៣សេះ |
| | | | |

- ឧបករណ៍នេសាទណានិងទូករបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ម៉ែត្រ | ២០ | ១៥០ម-៣០០ម/ គ្រួសារ | ៦០០០ម៉ែត្រ | ពេញមួយឆ្នាំ |
| សន្ទូចរនង | ផ្លែ | ១០ | ៥០០-១០០០ផ្លែ / គ្រួសារ | ១០០០០ផ្លែ | ខែកញ្ញា-ខែមករា |
| សន្ទូចបង្កៃ | ផ្លែ | ៥ | ៥០-២៥០ផ្លែ / គ្រួសារ | ១២៥០ផ្លែ | ខែវិច្ឆិកា-ខែមករា |
| លាន់ | គ្រឿង | ៥ | ៥០-៦០គ្រឿង/គ្រួសារ | ៣០០គ្រឿង | ខែកញ្ញា-ខែវិច្ឆិកា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កម្លាំងសេះ |
|---|---|---|---|
| ទូកម៉ាស៊ីន | ១០០គ្រឿង | ២០០-៥០០គីឡូក្រាម | ៦,៥-១៣សេះ |
| | | | |

គ- ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ(គិតជាគីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីចម្រុះ | ១២០០គីឡូក្រាម | ១៦៨០គីឡូក្រាម | ២៨៨០គីឡូក្រាម |
| វារីសត្វ (ខ្យង លៀស) | គ្មាន | | |

## ៥. ផែនការគ្រប់គ្រងសហគមន៍នេសាទ

ក- ទស្សនៈវិស័យ

សហគមន៍នេសាទក្រូចឆ្មារមានទស្សនៈវិស័យរួមចំណែកគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌និងចីរភាពដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ខ- គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលជាកន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី និងការពារទំនាបលិចទឹកក្នុងរដូវតំឡើង និងនាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌។
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទតាមរយៈការអភិវឌ្ឍចម្រុះ ដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ និងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ។

គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ប្រភេទឧបករណ៍អនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន (ក្នុងពេលតែមួយ) | |
| ១.បឹងអាទាំង | តុលា-ឧសភា | មងរាយ | ២០០ម/គ្រួសារ | ៨០០០ម៉ែត្រ/៣០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | មិថុនា-កញ្ញា | | ១៥០ម/គ្រួសារ | ៦០០០ម៉ែត្រ/២០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កញ្ញា-មករា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ២០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-មករា | សន្ទូចបង្កៃ | ១០០ផ្លែ/គ្រួសារ | ២០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-ឧសភា | លប | ១០គ្រឿង/គ្រួសារ | ១០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កញ្ញា-វិច្ឆិកា | លាន់ | ៥០គ្រឿង/គ្រួសារ | ៥គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| ២.បឹងផ្អះ | តុលា-ឧសភា | មងរាយ | ២០០ម/គ្រួសារ | ៨០០០ម៉ែត្រ/១៥គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | មិថុនា-កញ្ញា | | ១៥០ម/គ្រួសារ | ៦០០០ម៉ែត្រ/១០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កញ្ញា-មករា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ១០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-មករា | សន្ទូចបង្កៃ | ១៥០ផ្លែ/គ្រួសារ | ១០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-ឧសភា | លប | ១០គ្រឿង/គ្រួសារ | ៥គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កញ្ញា-វិច្ឆិកា | លាន់ | ៥០គ្រឿង/គ្រួសារ | ៣គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| ៣.បឹងជុំសែន | តុលា-ឧសភា | មងរាយ | ២០០ម/គ្រួសារ | ៨០០០ម៉ែត្រ/១៥គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |

| | | | | | |
|---|---|---|---|---|---|
| | មិថុនា-កញ្ញា | | ១៥០ម/គ្រួសារ | ៦០០០ម៉ែត្រ/<br>១០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កញ្ញា-មករា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ១០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-មករា | សន្ទូចបង្កៃ | ១៥០ផ្លែ/គ្រួសារ | ១០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-ឧសភា | លប | ១០គ្រឿង/គ្រួសារ | ៥គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កញ្ញា-វិច្ឆិកា | លាន់ | ៥០គ្រឿង/គ្រួសារ | ៣គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| ៤.បឹងខ្សង | តុលា-ឧសភា | មងរាយ | ២០០ម/គ្រួសារ | ៨០០០ម៉ែត្រ/<br>១៥គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | មិថុនា-កញ្ញា | | ១៥០ម/គ្រួសារ | ៦០០០ម៉ែត្រ/<br>១០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កញ្ញា-មករា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ១០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-មករា | សន្ទូចបង្កៃ | ១៥០ផ្លែ/គ្រួសារ | ១០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-ឧសភា | លប | ១០គ្រឿង/គ្រួសារ | ៥គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កញ្ញា-វិច្ឆិកា | លាន់ | ៥០គ្រឿង/គ្រួសារ | ៣គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| ៥.បឹងរាំង | តុលា-ឧសភា | មងរាយ | ២០០ម/គ្រួសារ | ៨០០០ម៉ែត្រ/<br>១៥គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | មិថុនា-កញ្ញា | | ១៥០ម/គ្រួសារ | ៦០០០ម៉ែត្រ/<br>១០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កញ្ញា-មករា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ១០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-មករា | សន្ទូចបង្កៃ | ១៥០ផ្លែ/គ្រួសារ | ១០គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-ឧសភា | លប | ១០គ្រឿង/គ្រួសារ | ៥គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កញ្ញា-វិច្ឆិកា | លាន់ | ៥០គ្រឿង/គ្រួសារ | ៣គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| ៦.បឹងក្រពើម៉ឺន | តុលា-ឧសភា | មងរាយ | ២០០ម/គ្រួសារ | ៨០០០ម៉ែត្រ/<br>៨គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |

| | | | | | |
|---|---|---|---|---|---|
| | មិថុនា-កញ្ញា | | ១៥០ម/គ្រួសារ | ៦០០០ម៉ែត្រ/<br>៦គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កញ្ញា-មករា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ៤គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-មករា | សន្ទូចបង្កៃ | ១៥០ផ្លែ/គ្រួសារ | ៤គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-ឧសភា | លប | ១០គ្រឿង/គ្រួសារ | ៤គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កញ្ញា-វិច្ឆិកា | លាន់ | ៥០គ្រឿង/គ្រួសារ | ៤គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| ៧.បឹងកក់ | តុលា-ឧសភា | មងរាយ | ២០០ម/គ្រួសារ | ៨០០០ម៉ែត្រ/<br>៨គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | មិថុនា-កញ្ញា | | ១៥០ម/គ្រួសារ | ៦០០០ម៉ែត្រ/<br>៥គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កញ្ញា-មករា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ៥គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-មករា | សន្ទូចបង្កៃ | ១៥០ផ្លែ/គ្រួសារ | ៥គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-ឧសភា | លប | ១០គ្រឿង/គ្រួសារ | ៣គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កញ្ញា-វិច្ឆិកា | លាន់ | ៥០គ្រឿង/គ្រួសារ | ២គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| ៨.បឹងប្រឆេះ | តុលា-ឧសភា | មងរាយ | ២០០ម/គ្រួសារ | ៨០០០ម៉ែត្រ/<br>៨គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | មិថុនា-កញ្ញា | | ១៥០ម/គ្រួសារ | ៦០០០ម៉ែត្រ/<br>៥គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កញ្ញា-មករា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ៥គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-មករា | សន្ទូចបង្កៃ | ១៥០ផ្លែ/គ្រួសារ | ៥គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-ឧសភា | លប | ១០គ្រឿង/គ្រួសារ | ៣គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កញ្ញា-វិច្ឆិកា | លាន់ | ៥០គ្រឿង/គ្រួសារ | ២គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| ៩.បឹងតាមោក | តុលា-ឧសភា | មងរាយ | ២០០ម/គ្រួសារ | ៨០០០ម៉ែត្រ/<br>៤គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |

| | | | | | |
|---|---|---|---|---|---|
| | មិថុនា-កញ្ញា | | ១៥០ម/គ្រួសារ | ៦០០០ម៉ែត្រ/ ៣គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កញ្ញា-មករា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ២គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-មករា | សន្ទូចបង្កៃ | ១៥០ផ្លែ/គ្រួសារ | ២គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-ឧសភា | លប | ១០គ្រឿង/គ្រួសារ | ២គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កញ្ញា-វិច្ឆិកា | លាន់ | ៥០គ្រឿង/គ្រួសារ | ២គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| ១០.បឹងអូរកំប្រុក | សីហា-តុលា | មងរាយ | ២០០ម/គ្រួសារ | ៨០០០ម៉ែត្រ/ ៨គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-មីនា | | ១៥០ម/គ្រួសារ | ៦០០០ម៉ែត្រ/ ៦គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-មករា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ៤គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-មករា | សន្ទូចបង្កៃ | ១៥០ផ្លែ/គ្រួសារ | ៤គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កក្កដា-កញ្ញា | លប | ១០គ្រឿង/គ្រួសារ | ៤គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កញ្ញា-វិច្ឆិកា | លាន់ | ៥០គ្រឿង/គ្រួសារ | ៤គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| ១១.បឹងតូច | សីហា-តុលា | មងរាយ | ២០០ម/គ្រួសារ | ៨០០០ម៉ែត្រ/ ៨គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-មីនា | | ១៥០ម/គ្រួសារ | ៦០០០ម៉ែត្រ/ ៥គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-មករា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ៥គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-មករា | សន្ទូចបង្កៃ | ១៥០ផ្លែ/គ្រួសារ | ៥គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កក្កដា-កញ្ញា | លប | ១០គ្រឿង/គ្រួសារ | ៣គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កញ្ញា-វិច្ឆិកា | លាន់ | ៥០គ្រឿង/គ្រួសារ | ២គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| ១២.ព្រៃកតាខ្លូង | សីហា-តុលា | មងរាយ | ២០០ម/គ្រួសារ | ៨០០០ម៉ែត្រ/ ២គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |

| | | | | | |
|---|---|---|---|---|---|
| | វិច្ឆិកា-មីនា | | ១៥០ម/គ្រួសារ | ៦០០០ម៉ែត្រ/ ១គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-មករា | សន្ទូចបង្កៃ | ១៥០ផ្លែ/គ្រួសារ | ២គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-មករា | លប | ១០គ្រឿង/គ្រួសារ | ១គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កក្កដា-កញ្ញា | លាន់ | ៥០គ្រឿង/គ្រួសារ | ១គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| ១៣.ព្រៃកចាស់ | សីហា-តុលា | មងរាយ | ២០០ម/គ្រួសារ | ៨០០០ម៉ែត្រ/ ២២គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-មីនា | | ១៥០ម/គ្រួសារ | ៦០០០ម៉ែត្រ/ ១៤គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-មករា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ១៤គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | វិច្ឆិកា-មករា | សន្ទូចបង្កៃ | ១៥០ផ្លែ/គ្រួសារ | ១៤គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កក្កដា-កញ្ញា | លប | ១០គ្រឿង/គ្រួសារ | ១៤គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |
| | កញ្ញា-វិច្ឆិកា | លាន់ | ៥០គ្រឿង/គ្រួសារ | ៦គ្រួសារ | -សមាជិកស.ន<br>-មិនមែនសមាជិកស.ន |

គ២-ផែនការកែលំអដែននេសាទ

ផែនការការលំអដែននេសាទ ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម ៖

| ឈ្មោះដែន នេសាទ | ទំហំ (ហិកតា) | ទំហំ ដែល ត្រូវកែលំអ | សកម្មភាព | ប៉ាន់ស្មាន តម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| បឹងអាទាំង | ១០ | ២ហិកតា<br>200មx100ម | ជីកកាយយកដីល្បាប់ ស្រទាប់បាតកន្លែង អភិរក្សឲ្យបានជម្រៅទឹក ២,៥-៣មនៅរដូវប្រាំង | ១៥០០០ | ១/៣/១៩ | ១/៤/២១ |

គ៣-ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម ៖

| ឈ្មោះដែននេសាទ | ទំហំដែលត្រូវអភិរក្ស(ហ.ត) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ស្មានតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| អន្លង់បឹងអាទាំង | ២ហិកតា (ប=២០០មx ទ=១០០ម) | អភិរក្សត្រីមេពូជ | បោះបង្គោលស៊ីម៉ងត៍ (7mX0.15mx0.15m) ចំនួន៣០ដើមព័ទ្ធជុំវិញកន្លែងអភិរក្សក្នុងចន្លោះ ២០ម៉ែត្របោះ១បង្គោល | ៣០០០ | ១/៣/១៩ | ១/៥/២០ |
| | | | ធ្វើស្លាកសញ្ញាអភិរក្សចំនួន៤ផ្ទាំងដាក់នៅជាប់ព្រំប្រទល់កន្លែងអភិរក្ស | ៥០០ | ១/៤/១៩ | ១/៦/២០ |
| | | | ទម្លាក់គល់ឈើចំនួន ២០០គល់ចូលក្នុងកន្លែងអភិរក្សត្រីមេពូជ | ៣០០០ | ១/៣/១៩ | ១/៥/២០ |
| | | | សាងសង់ស្នាក់ការបណ្តែតទឹកដើម្បីការពារកន្លែងអភិរក្សត្រីមេពូជ | ១៥០០ | ១/៥/១៩ | ១/៧/២០ |

គ៤-ផែនការល្បាតទប់ស្កាត់បទល្មើសជលផល

ផែនការល្បាតទប់ស្កាត់បទល្មើសជលផល ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | គោលបំណង | អ្នកចូលរួមអនុវត្តន៍ | ប៉ាន់ស្មានតម្លៃ(ដុល្លារ) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ទិញទូកស្នាច់០៣គ្រឿងប្រវែង៨ម៉ែត្រនិងម៉ាស៊ីនទូកកម្លាំង១៧សេះ | ចុះល្បាតការពារនិងទប់ស្កាត់បទល្មើសជលផលក្នុងកន្លែងនេសាទស.ន | - គណកម្មការនិង<br>- ក្រុមល្បាតសហគមន៍ស.ន | ៣៥០០ | ២០១៩ | ២០២១ |
| ទិញឧបករណ៍សម្ភារៈសម្រាប់ចុះល្បាត( អាវពោងសុវត្ថិភាព អាគុយ អំពូលភ្លើងហ្វា ទូរស័ព្ទវិទ្យុទាក់ទង ម៉ាស៊ីនថតពិលអាវភ្លៀង កែវយឺតមេក្រូ ប្រេងសាំង ប្រេងម៉ាស៊ីន,..។ | - ប្រើប្រាស់សម្រាប់ចុះល្បាត តាមដាន ត្រួតពិនិត្យ ទប់ស្កាត់បទល្មើសជលផលក្នុងកន្លែងនេសាទស.ន | - គណកម្មការនិង<br>- ក្រុមល្បាតសហគមន៍ស.ន | ១៥០០ | ២០១៩ | ២០២១ |

| | | | | | |
|---|---|---|---|---|---|
| រៀបចំក្រុមល្បាតនិងបែងចែកតាមវេនចុះល្បាតប្រចាំថ្ងៃនិងប្រចាំសប្ដាហ៍ | - ឲ្យមានក្រុម និងវេនចុះល្បាតឲ្យបានទៀងទាត់ជាប្រចាំ | - គណកម្មការ និង<br>- ក្រុមល្បាតសហគមន៍ស.ន | ១០០០ | ២០១៩ | ២០២១ |
| -ផ្សព្វផ្សាយតាមមេក្រូចំនួន៦ដងក្នុងមួយឆ្នាំ<br>-បិទលិខិតបទដ្ឋាបគតិយុត្តផ្សព្វផ្សាយចំនួន២ដង១ដងក្នុងមួយឆ្នាំ | បង្កើនការយល់ដឹងអំពីឧបករណ៍នេសាទស្របច្បាប់ ឧបករណ៍នេសាទហាមឃាត់ និងការពារកន្លែងអភិរក្សត្រីមេពូជ | - គណកម្មការ និង<br>- ក្រុមល្បាតសហគមន៍ស.ន<br>- អាជ្ញាធរភូមិ ឃុំ | ៥០០ | ២០១៩ | ២០២១ |

គ៥-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទវារីវប្បកម្ម | ចំនួនគ្រួសារ | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ចិញ្ចឹមត្រីក្នុងស្រះ | ៥០ | ត្រីប្រា | ៣០០០០០កូនត្រី | ១/២/១៩ | ១/៦/២១ |
| ចិញ្ចឹមត្រីក្នុងស្រះ | ៥០ | ត្រីទីឡាព្យាក្រហម | ១២៧៥០០កូនត្រី | ១/៣/១៩ | ១/៦/២១ |
| ចិញ្ចឹមក្នុងតង់កៅស៊ូ | ៥០ | ត្រីអណ្តែង | ២៨០០០កូនត្រី | ១/៤/១៩ | ១/៦/២១ |
| ចិញ្ចឹមក្នុងតង់កៅស៊ូ | ៥០ | កង្កែប | ៤០០០០កូនកង្កែប | ១/៤/១៩ | ១/៩/២១ |
| ចិញ្ចឹមក្នុងតង់កៅស៊ូ | ២៥ | អន្ទង់ | ១៨០០០កូនអន្ទង់ | ១/១/១៩ | ១/១០/២១ |

គ៦-ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ

ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| វគ្គបណ្តុះបណ្តាល និងទិវាអភិរក្ស | គោលបំណង | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| ក. វគ្គបណ្តុះបណ្តាល | | | | |
| ច្បាប់ស្តីពីជលផល អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងស.ន | បង្កើនយល់ដឹងអំពីខ្លឹមសារនៃលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលជលផល | -គណកម្មការ និងសមាជិកសហគមន៍<br>-អាជ្ញាធរភូមិ ឃុំ | ២០១៩ | ២០២១ |
| ជំនាញសម្របសម្រួល និងជំនាញដោះស្រាយទំនាស់ | មានចំណេះដឹងក្លាយជាអ្នកសម្របសម្រួល និងចេះដោះស្រាយទំនាស់បានល្អ | | ២០១៩ | ២០២១ |

| | | | | |
|---|---|---|---|---|
| របៀបសរសេរលិខិតរដ្ឋបាល(របាយការណ៍ និងកំណត់ហេតុ) | មានចំណេះដឹងអំពីសរសេរ និងគ្រប់គ្រងលិខិតរដ្ឋបាល | | ២០១៩ | ២០២១ |
| របៀបរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងធ្វើផែនការអនុវត្តន៍សកម្មភាពគម្រោង | មានចំណេះដឹងអំពីរបៀបធ្វើផែនការសហគមន៍ និងផែនអនុវត្តន៍សកម្មភាពគម្រោង | | ២០១៩ | ២០២១ |
| របៀបសរសេរគម្រោងស្នើសុំថវិកា និងធ្វើផែនការគ្រប់គ្រងថវិកាស.ន និងរបៀបស្វែងរកថវិកា | មានចំណេះដឹងអំពីរបៀបសរសេរគម្រោងស្នើសុំថវិកា និងការធ្វើផែនការគ្រប់គ្រង និងយុទ្ធសាស្ត្រស្វែងរកថវិកា | | ២០១៩ | ២០២១ |
| - កសាងភាពជាដៃគូ និងបណ្តាញ<br>- ភាពជាអ្នកដឹកនាំ | -មានចំណេះដឹងអំពីសារៈប្រយោជន៍កសាងភាពជាដៃគូ និងបណ្តាញ<br>-ក្លាយទៅជាអ្នកដឹកនាំស.នល្អ | | ២០១៩ | ២០២១ |
| ប្រភេទនៃអ្នកចូលរួមក្នុងការអភិវឌ្ឍ | មានចំណេះដឹងអំពីការជ្រើសរើស និងធ្វើការជាមួយអ្នកចូលរួមពិតប្រាកដក្នុងការអភិវឌ្ឍសហគមន៍មូលដ្ឋាន | | ២០១៩ | ២០២១ |
| **ខ. ទិវាអភិរក្ស និងផ្សព្វផ្សាយ** | | | | |
| ការបង្កើត និងសារប្រយោជន៍នៃការគ្រប់គ្រងកន្លែងអភិរក្សត្រីមេពូជ | ឲ្យមានការចូលរួមពីសមាជិកស.ន និងប្រជាពលរដ្ឋទូទៅ ដើម្បីបង្កើនការយល់ដឹងតាមរយៈបង្កើតជាសំណួរ ចម្លើយ លេងល្បែងប្រាជ្ញា និងផ្សព្វផ្សាយអំពីការបង្កើត និងសារៈប្រយោជន៍នៃកន្លែងអភិរក្ស | -គណកម្មការស.ន<br>-សមាជិកសហគមន៍នេសាទ<br>-មិនមែនសមាជិកសហគមន៍<br>-អាជ្ញាធរភូមិ ឃុំ<br>-ប្រជាពលរដ្ឋទូទៅ | ២០១៩ | ២០២១ |
| គុណតម្លៃនៃព្រៃលិចទឹក និងការគ្រប់គ្រងព្រៃលិចទឹក | ឲ្យមានការចូលរួមពីសមាជិកស.ន និងប្រជាពលរដ្ឋទូទៅ ដើម្បីបង្កើនការយល់ដឹងតាមរយៈបង្កើតជាសំណួរ ចម្លើយ លេងល្បែងប្រាជ្ញា និងផ្សព្វផ្សាយអំពីគុណតម្លៃ និងការគ្រប់គ្រងព្រៃលិចទឹក | | ២០១៩ | ២០២១ |
| ការធ្វើនេសាទប្រកបដោយនិរន្តរភាពក្នុងកន្លែងនេសាទសហគមន៍ | ឲ្យមានការចូលរួមពីសមាជិកស.ន និងប្រជាពលរដ្ឋទូទៅ ដើម្បីបង្កើនការយល់ដឹងតាមរយៈបង្កើតជាសំណួរ ចម្លើយ លេងល្បែងប្រាជ្ញា និងផ្សព្វ | | ២០១៩ | ២០២១ |

| | | | | |
|---|---|---|---|---|
| | ផ្សាយអំពីការធ្វើនេសាទប្រកបដោយនិរន្តរភាព | | | |
| ផលប្រយោជន៍នៃការចូលរួមក្នុងសហគមន៍នេសាទ | ឲ្យមានការចូលរួមពីសមាជិក ស.ន និងប្រជាពលរដ្ឋទូទៅ ដើម្បីបង្កើនការយល់ដឹងតាមរយៈបង្កើតជាសំណួរ ចម្លើយ លេងល្បែងប្រាជ្ញា និងផ្សព្វផ្សាយអំពីផលប្រយោជន៍នៃការចូលរួមក្នុងសហគមន៍ | | ២០១៩ | ២០២១ |

គ៧-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ដូចមាននៅក្នុងតារាងខាងក្រោម ៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំចាប់បញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍នេសាទ | -ផ្សព្វផ្សាយអំពីភារកិច្ច និងផលប្រយោជន៍នៃការចូលជាសមាជិកស.ន<br>-រៀបចំបញ្ជីគណនេយ្យ<br>-ប្រមូលប្រាក់ភាគទានសុំចូលជាសមាជិកស.នចាស់ និងថ្មី | ១/១/១៩ | ១/១/២១ | ១២៥ | ១០០០៛/១នាក់ សមាជិកចាស់/ថ្មី អាច៥០០នាក់ រយៈពេល៣ឆ្នាំ |
| ភាគទានប្រចាំឆ្នាំ | -ផ្សព្វផ្សាយអំពីការបង់ប្រាក់ភាគទានប្រចាំឆ្នាំ<br>-ប្រមូលភាគទានប្រចាំឆ្នាំ | ១/១/១៩ | ១/១/២១ | ១៥០០ | -២០០០០៛ ៖សមាជិកធ្វើនេសាទជាអាជីព<br>-៥០០០៛ ៖សមាជិកធ្វើនេសាទម្តងម្កាល<br>-១០០០៛ ៖ ចំពោះសមាជិកគាំទ្រ មិនធ្វើនេសាទ<br>-...៛? ៖ មិនមែនជាសមាជិកស.នតែធ្វើនេសាទជាអាជីព |
| -ជំនួយសប្បុរសជន<br>-អង្គការនានា<br>-ជំនួយរាជរដ្ឋាភិបាល | -រៀបចំសរសេរគម្រោងស្នើសុំថវិកា និងស្វែងរកអង្គការដៃគូអភិវឌ្ឍន៍នានា<br>-ធ្វើគម្រោងផែនការស.នសុំដាក់បញ្ចូលសមាហរណកម្មក្នុងផែនការអភិវឌ្ឍន៍ឃុំ | ១/១/១៩ | ១/១/២១ | ៤២៥០០ | ១៤១៦៧ដុល្លារ/ឆ្នាំ |
| | | | គម្រោងថវិកាសរុប | ៤៤១២៥$ | រយៈពេល៣ឆ្នាំ |

ឃ- ផែនការយុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ រួមមានសមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំដែលមានបទពិសោធន៍ និងចំណេះដឹងល្អៗជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួញបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនិងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកស្វែងថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំផែនការអនុវត្តតាមដំណាក់កាលនិមួយៗដោយជាក់លាក់ និងផែនការសកម្មភាពប្រចាំឆ្នាំ
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកានិងជួយរកដៃគូអភិវឌ្ឍន៍សម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍នេសាទ
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងផែនការអភិ

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ក្រូចឆ្មារ រយៈពេល ៣ឆ្នាំ (២០១៩ដល់២០២១)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ (ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ប្រជុំពិគ្រោះយោបល់អំពីការប្រើប្រាស់ឧបករណ៍នេសាទឲ្យសមស្រប និងកំណត់ទីកន្លែងនេសាទឲ្យបានច្បាស់លាស់. | -ធ្វើនេសាទប្រកបដោយនិរន្តរភាព<br>-បង្កើនប្រាក់ចំណូលពីផលនេសាទ<br>-ធនធានជលផលកើនឡើង | ៥០០០ | -រាជរដ្ឋាភិបាលតាមរយៈមន្ទីរកសិកម្មខេត្តឬរដ្ឋបាលជលផលឬអាជ្ញាធររដ្ឋបាល ឃុំ<br>-អង្គការដៃគូអភិវឌ្ឍន៍នានា<br>-សហគមន៍នេសាទ<br>-សប្បុរសជន | ២០១៩ | ២០២១ | |
| គ២-ផែនការកែលំអដែននេសាទ | ជីកកាយយកដីល្បាប់ស្រទាប់បាតកន្លែងអភិរក្សឲ្យបានជម្រៅទឹក២,៥ម៉ែត្រក្នុងរដូវប្រាំង | -នៅកន្លែងអភិរក្សត្រីមេពូជ នឹងមានជម្រៅទឹកសមស្រប ដែលអាចឲ្យផលស្តុកត្រីគ្រប់ប្រភេទកើនឡើង | ១៥០០០ | | ២០១៩ | ២០២១ | |
| គ៣-ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស | បោះបង្គោលស៊ីម៉ងតិ៍ចំនួន៣០ដើមដាក់ព័ទ្ធជុំវិញកន្លែងអភិរក្សទំហំ២ហិកតា(200មX100ម) | -មានព្រំប្រទល់កន្លែងអភិរក្ស<br>-បែងចែកបានច្បាស់រវាងកន្លែងនេសាទ និងកន្លែងអភិរក្សត្រីមេពូជ | ៣០០០ | | ២០១៩ | ២០២១ | |
| | ធ្វើស្លាកសញ្ញាអភិរក្សចំនួន៤ផ្ទាំងដាក់នៅជាប់ព្រំប្រទល់កន្លែងអភិរក្ស | មានសញ្ញាសម្គាល់អំពីហាមឃាត់ចូលធ្វើនេសាទ និងហាមបើកបរទូកឆ្លងកាត់ខាងក្នុងកន្លែងអភិរក្ស | ៥០០ | | ២០១៩ | ២០២១ | |
| | ទម្លាក់គល់ឈើចំនួន២០០គល់ចូលក្នុងកន្លែងអភិរក្សត្រីមេពូជ | មានជម្រកសប្បនិម្មិតត្រីមេពូជសម្រាប់រស់នៅធំលូតលាស់បន្តពូជពងកូននិងការពារមិនលួចនេសាទ | ៣០០០ | | ២០១៩ | ២០២១ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | សាងសង់ស្នាក់ការបណ្តែតទឹកដើម្បីការពារកន្លែងអភិរក្សត្រីមេពូជ | មានស្នាក់ការបណ្តែតទឹកសម្រាប់យាមល្បាតការពារមិនឲ្យចូលនេសាទក្នុងកន្លែងអភិរក្សត្រីមេពូជ និងទប់ស្កាត់ការប្រើប្រាស់ឧបករណ៍នេសាទហាមឃាត់ | ១៥០០ | | ២០១៩ | ២០២១ | |
| គ៤-ផែនការល្បាតទប់ស្កាត់បទល្មើសជលផល | -ទិញទូកស្នាច់០៣គ្រឿងប្រវែង៨ម៉ែត្រនិងម៉ាស៊ីនទូកមានកម្លាំង១៧សេះ<br>-ទិញឧបករណ៍សម្ភារៈសម្រាប់ចុះល្បាត<br>-រៀបចំក្រុមល្បាត និងបែងចែកវេនចុះល្បាត<br>-ផ្សព្វផ្សាយតាមមេក្រូ៦ដងក្នុងមួយឆ្នាំ និងបិទលិខិតបទដ្ឋានគតិយុត្តផ្សព្វផ្សាយ២ដងក្នុង១ឆ្នាំ | -មានទូកម៉ាស៊ីន និងឧបករណ៍សម្ភារៈសម្រាប់ចុះល្បាតទប់ស្កាត់បទល្មើស<br>-ប្រជានេសាទទូទៅ និងសមាជិកសហគមន៍នេសាទបានយល់ដឹងអំពីការប្រើប្រាស់ឧបករណ៍នេសាទស្របច្បាប់នៅក្នុងកន្លែងសហគមន៍នេសាទ និងបទល្មើសនេសាទថយចុះ | ៦៥០០ | | ២០១៩ | ២០២១ | |
| គ៥-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | -បើកវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសចិញ្ចឹមត្រី កង្កែប អន្ទង់ជាលក្ខណៈពាណិជ្ជកម្មនៅក្នុងស្រះ បែ និងតង់កៅស៊ូ។ | សមាជិកសហគមន៍នេសាទចំនួនប្រហែល២០០គ្រួសារមានចំណេះដឹងបច្ចេកទេសចិញ្ចឹមត្រី កង្កែប អន្ទង់លក្ខណៈពាណិជ្ជកម្មនៅក្នុងស្រះ បែ និងតង់កៅស៊ូ។ | ៥០០០ | | ២០១៩ | ២០២១ | |
| គ៦-ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ | -បណ្តុះបណ្តាលអំពីលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសហគមន៍នេសាទ និងពង្រឹងសមត្ថភាព | - គណកម្មការ និងសមាជិកសហគមន៍បានយល់ដឹងអំពីលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសហគមន៍នេសាទ និងមានសមត្ថភាព | ៣០០០ | | ២០១៩ | ២០២១ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | គណៈកម្មការ និងសមាជិកសហគមន៍នេសាទ។<br>-ធ្វើទិវាអភិរក្ស និងផ្សព្វផ្សាយដើម្បីបង្កើនការយល់ដឹងតាមរយៈបង្កើតជាសំណួរ ចម្លើយ និងលេងល្បែងប្រាជ្ញា ដែលទាក់ទងកន្លែងអភិរក្សត្រីមេពូជ ព្រៃលិចទឹក និងផលប្រយោជន៍នៃការចូលរួមក្នុងសហគមន៍នេសាទ | ក្លាយជាអ្នកដឹកនាំល្អ ឫជាគ្រូបង្គោលក្នុងសហគមន៍មូលដ្ឋាន<br>- សមាជិកសហគមន៍ និងប្រជាពលរដ្ឋមូលដ្ឋានបានយល់ដឹងអំពីសារប្រយោជន៍នៃកន្លែងអភិរក្សត្រីមេពូជ ព្រៃលិចទឹក និងផលប្រយោជន៍នៃការចូលរួមក្នុងសហគមន៍នេសាទ។ | | | - | | |
| គ៧-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | -ផ្សព្វផ្សាយអំពីភារកិច្ច និងផលប្រយោជន៍នៃការចូលជាសមាជិកសហគមន៍<br>-ប្រមូលការបង់ប្រាក់ភាគទានសុំចូលជាសមាជិក ស.ន និងអ្នកសុំចូលថ្មី<br>-ធ្វើគម្រោងស្នើសុំថវិកា និងស្វែងរកអង្គការដៃគូអភិវឌ្ឍន៍នានា<br>-យកផែនការនេះ សុំដាក់បញ្ចូលសមាហរណកម្មក្នុងផែនការអភិវឌ្ឍន៍ឃុំ | ទទួលបានថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍តាមគម្រោងផែនការ | ៤៤១២៥ | -សមាជិក និងមិនមែនសមាជិកសហគមន៍នេសាទ<br>-រាជរដ្ឋាភិបាលតាមរយៈមន្ទីរកសិកម្មខេត្ត ឫរដ្ឋបាលជលផល ឫអាជ្ញាធររដ្ឋបាលឃុំ<br>-អង្គការដៃគូអភិវឌ្ឍន៍នានា<br>-សហគមន៍នេសាទ<br>-សប្បុរសជន | ១/១/១៩ | ១/១/២១ | |

## កាលវិភាគកម្មវិធីការងារ

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | | | | | | | ២០២០ | | | ២០២១ | | |
| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា | ... | ធ្នូ | មករា | ... | ធ្នូ |
| គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | → |
| គ២-ផែនការកែលំអដែននេសាទ | | — | — | → | | | | | | | | | → | | | → | | |
| គ៣-ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស | | | — | — | — | — | → | | | | | | → | | | | | |
| គ៤-ផែនការល្បាតទប់ស្កាត់បទល្មើសជលផល | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | → |
| គ៥-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | | | | | — | — | — | — | — | — | — | — | → | - - | - - | - - → | - - | → |
| គ៦-ផែនការពង្រឹងសមត្ថភាពសហគមន៍នេសាទ | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | → |
| គ៧-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | → |

សូមគោរពជូន

លោកមេឃុំក្រូចឆ្មារ

"ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ............ ខែ............ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ខ្សាច់ប្រឆេះក្រោម ថ្ងៃទី ខែ ឆ្នាំ២០១៨

ប្រធានគណៈកម្មការសហគមន៍នេសាទក្រូចឆ្មារ

[signature] សេង ព្រៅ

លេខ : 138/18

បានឃើញ និងគោរពជូន

លោកនាយផ្នែករដ្ឋបាលជលផលត្បូងឃ្មុំ

"ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ............ ខែ............ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ខ្សាច់ប្រឆេះលើ ថ្ងៃទី ខែ ឆ្នាំ២០១៨

មេឃុំក្រូចឆ្មារ

[stamp, signature] ឡៀង ឈុនហ៊ាង

បានឃើញ និងគោរពជូន

លោកនាយខណ្ឌរដ្ឋបាលជលផលត្បូងឃ្មុំ

"ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ត្បូងឃ្មុំ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨

នាយផ្នែករដ្ឋបាលជលផលត្បូងឃ្មុំ

[signature]

លេខ : ១៣៤

បានឃើញ និងគោរពជូន

លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តត្បូងឃ្មុំ

"ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ … ខែ … ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

ត្បូងឃ្មុំ ថ្ងៃទី២៦ ខែ… ឆ្នាំ២០១៨

**នាយខណ្ឌរដ្ឋបាលជលផលត្បូងឃ្មុំ**

**អៀម_ម៉ាយុទ្ធី**

លេខ …

បានឃើញ និងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

"ដើម្បីជូនពិនិត្យ និងសម្រេចដោយអនុគ្រោះ"

ថ្ងៃ … ខែ … ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ត្បូងឃ្មុំ ថ្ងៃទី០៦ ខែ… ឆ្នាំ២០១៨

ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តត្បូងឃ្មុំ

**ហេង ពិសិដ្ឋ**

លេខ : ២៤២៨

បានឃើញ និងឯកភាព

ថ្ងៃ … ខែ … ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៨

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**